# អាស៊ីដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់ត្រូវការគោលនយោបាយ ម៉ាក្រូប្រុងប្រយ័ត្នកាន់តែរឹងមាំដើម្បីកាត់បន្ថយហានិភ័យពី ការប្រែប្រួលអាកាសធាតុ និងការកើនឡើងនៃ Fintech

ប៉ារីស ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ – "គោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នកំពុងមានការកើនឡើងនៅអាស៊ីដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់ ហើយវាដើរតួនាទីដ៏សំខាន់ក្នុងការគាំទ្រដល់ការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចកាបូនទាប និងឌីជីថល" ដែលនេះជាការលើកឡើងរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD នៅក្នុងរបាយការណ៍របស់ខ្លួនស្តីពី *ការពង្រឹងគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ននៅអាស៊ីដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់៖ សម្របខ្លួនទៅនឹងគោលដៅបៃតង និង Fintech* ដែលបានចេញផ្សាយនៅថ្ងៃនេះ។

របាយការណ៍នេះផ្តល់នូវទិដ្ឋភាពទូទៅយ៉ាងគ្រប់ជ្រុងជ្រោយអំពីបទពិសោធន៍របស់តំបន់នេះជាមួយគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន ដែលជាវិធានការសំដៅកាត់បន្ថយហានិភ័យជាប្រព័ន្ធ និងរក្សាស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ មក។ អាជ្ញាធរគោលនយោបាយនៅអាស៊ីដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់បានដាក់ចេញវិធានការបែបនេះបន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ចធំៗពីរដែលបានជះឥទ្ធិពលដល់តំបន់នេះក្នុងទសវត្សរ៍កន្លងទៅនេះ។ ថ្មីៗនេះ ប្រទេសជាច្រើនបានប្រែក្លាយកំណែទម្រង់បទប្បញ្ញត្តិធនាគារ បាហ្សល III ទៅជាច្បាប់ជាតិរបស់ពួកគេ ហើយបានរុះរើស្ថាប័ន និងការកំណត់រចនាសម្ព័ន្ធម៉ាក្រូប្រុងប្រយ័ត្នរបស់ខ្លួន។

របាយការណ៍នេះកំណត់នូវបញ្ហាប្រឈមសំខាន់ៗដែលអាជ្ញាធរនៅអាស៊ីដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់អាចជួបប្រទះក្នុងការសម្រេចគោលនយោបាយបែបនេះប្រកបដោយប្រសិទ្ធភាព និងបង្កើតជាអនុសាសន៍ដើម្បីជម្នះបញ្ហាប្រឈមទាំងនោះ៖ នៅពេលវាយតម្លៃប្រសិទ្ធភាពនៃគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន ផ្តល់ការពិចារណាសមស្របអំពីការភ្ជាប់ទំនាក់ទំនងដ៏ស្មុគស្មាញរបស់វាជាមួយគោលនយោបាយរូបិយវត្ថុ ពិចារណាអំពីការកើនឡើងនៃអន្តរទំនាក់ទំនងរវាងអន្តរការីធនាគារ និងមិនមែនធនាគារ ផ្តល់ការពិចារណាសមស្របអំពីផលប៉ះពាល់ឆ្លងព្រំដែន កំណត់គោលដៅគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នឱ្យមានប្រសិទ្ធភាពបំផុតដើម្បីចៀសវាងគ្រោះថ្នាក់ខាងសីលធម៌ ចាត់ថ្នាក់នូវផលវិបាកនៃវិបត្តិកូវីដ-១៩ រៀបចំដោយប្រុងប្រយ័ត្ននូវក្របខណ្ឌសម្រាប់វាស់ស្ទង់ជំហរម៉ាក្រូប្រុងប្រយ័ត្នរបស់ប្រទេស។

ហានិភ័យដែលជាប់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុមានអស្ថិរភាពធ្ងន់ធ្ងរនៅក្នុងបណ្តាប្រទេសអាស៊ីដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់។ ដូច្នេះធនាគារកណ្តាល

ចាំបាច់ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ហើយអ្នកធ្វើគោលនយោបាយចាំបាច់ត្រូវកែប្រែ ឬពង្រីកសំណុំឧបករណ៍គោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នរបស់ខ្លួនដើម្បីដោះស្រាយហានិភ័យជាប្រព័ន្ធដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ និងគាំទ្រដល់ការវិនិយោគកាបូនទាប។ ជម្រើសគោលនយោបាយនានារួមមានការរួមបញ្ចូលហានិភ័យដែលទាក់ទងនឹងអាកាសធាតុទៅក្នុងការធ្វើតេស្តភាពតានតឹងនៃម៉ាក្រូប្រុងប្រយ័ត្ន។ វាក៏រួមមានផងដែរនូវលិខិតុបករណ៍ដែលអាចកម្រិតយ៉ាងមានប្រសិទ្ធភាពនូវចំនួនប្រាក់កម្ចីរបស់ធនាគារចំពោះវិស័យកាបូនខ្ពស់ ខណៈដែលបង្វែរលំហូរឥណទានឡើងវិញទៅការវិនិយោគដែលល្អសម្រាប់អាកាសធាតុ។

ការកើនឡើងនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ *–Fintech-* ក៏នាំមកនូវបញ្ហាប្រឈមថ្មីៗផងដែរ រួមមាន៖ ឥរិយាបថប្រថុយប្រថានជាងមុន ភាពងាយប្រែប្រួលជាងមុននៅក្នុងវិស័យនេះ និងបដិអន្តរការីកម្ម។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ បណ្ដាប្រទេសអាស៊ីដែលកំពុងមានសេដ្ឋកិច្ចរីកលូតលាស់គួរតែពង្រឹងគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នដើម្បីធ្វើឱ្យបណ្ដាក្រុមហ៊ុន Fintech ស្ថិតនៅក្នុងដែននិយ័តកម្ម។ លើសពីនេះទៀត ដើម្បីចៀសវាងហានិភ័យពាក់ព័ន្ធនឹងសកម្មភាពឆ្លងព្រំដែនរបស់ Fintech និយ័តករទាំងឡាយគួរតែបង្កើនកិច្ចសហប្រតិបត្តិការតាមរយៈការរួបរួមនិយ័តកម្ម។

អ្នកសារព័ត៌មានសូមអញ្ជើញទាក់ទង Kensuke Tanaka ជាប្រធានប្រចាំតំបន់អាស៊ី នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD (Kensuke.Tanaka@oecd.org, +៣៣ ៦ ២៧ ១៩ ០៥ ១៩) ឬ Bochra Kriout នៅការិយាល័យសារព័ត៌មាននៃមជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD (Bochra.Kriout@oecd.org, +៣៣ ១ ៤៥ ២៤ ៨២ ៩៦)។